**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៣៣...សសរ**

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតគណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និង សេវាសុខាភិបាលខុសច្បាប់ដើម្បីកាត់បន្ថយភាពក្រីក្រ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតអោយជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។



www.pheakdeylaw.com

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការមួយដែលមានឈ្មោះ គណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដែលមានវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជាសម្រាប់កាត់បន្ថយភាពក្រីក្រ ។

គណៈកម្មាធិការមានគណៈកម្មការ២ ៖

**១.១ គណៈកម្មការអន្តរក្រសួង**

គណៈកម្មការអន្តរក្រសួងមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូបជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣. អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូបជាអនុប្រធាន |
| ៤. អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូបជាអនុប្រធាន |
| ៥. អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១ រូបជាសមាជិក |
| ៦. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ០១ រូបជាសមាជិក |
| ៧. អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ០១ រូបជាសមាជិក |
| ៨. អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូបជាសមាជិក |
| ៩. អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូបជាសមាជិក |
| ១០.អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូបជាសមាជិក |
| ១១.អភិបាលរងរាជធានីភ្នំពេញ | ០១ រូបជាសមាជិក |
| ១២.ប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល | ជាសមាជិក |
| ១៣.ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង នៃក្រសួងសុខាភិបាល | ជាលេខាធិការ |

**១.២ គណៈកម្មការខេត្ត-ក្រុង**

គណៈកម្មការខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១. អភិបាលរងខេត្ត ក្រុង | ជាប្រធាន |
| ២. ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣. អនុប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង | ០១ រូបជាសមាជិក |



www.pheakdeylaw.com

៤. តំណាងអយ្យការតុលាការខេត្ត ក្រុង ០១ រូបជាសមាជិក

៥. ស្នងការនគរបាលខេត្ត ក្រុង ជាសមាជិក

៦. ប្រធានមន្ទីរព័ត៌មានខេត្ត ក្រុង ជាសមាជិក

៧. ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ជាសមាជិក

៨. ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ជាសមាជិក

៩. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង ជាសមាជិក

១០.ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង ជាសមាជិក

១១.ប្រធានសាខាកាំកុងត្រូលខេត្ត ក្រុង ជាសមាជិក

១២.ប្រធានការិយាល័យបច្ចេកទេសនៃមន្ទីរសុខាភិបាល ជាសមាជិក

១៣.ប្រធានការិយាល័យឱសថ និងសុវត្ថិភាពចំណីអាហារ ជាលេខាធិការ

**ប្រការ ២.-**

គណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង និងអន្តរជាតិដើម្បីលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដែលបច្ចុប្បន្នកំពុងកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា
- ខិតខំស្វែងរកប្រភពនៃឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- ចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការត្រួតពិនិត្យជាប្រចាំដើម្បីឃាត់ទុក បំផ្លាញចោល និងទប់ស្កាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ឈានទៅលុបបំបាត់ជាស្ថាពរ
- ផ្សព្វផ្សាយ អប់រំ និងលើកកម្ពស់ការយល់ដឹងដល់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- រៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើស ។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាលដើម្បីសម្រួលការងារ ។

គណៈកម្មការខេត្ត ក្រុង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ដើម្បីសម្រួលការងារ ។



www.pheakdeylaw.com

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានលេខាធិការដ្ឋាននៅក្រសួងសុខាភិបាល ។

គណៈកម្មការខេត្ត ក្រុង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានលេខាធិការដ្ឋាននៅមន្ទីរសុខាភិបាលខេត្ត ក្រុង ។

**ប្រការ ៥.-**

បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង និងសមាជិកគណៈកម្មការខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានដើម្បីរាយការណ៍ពីសកម្មភាព និងលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៦.-**

រាល់ចំណាយរបស់គណៈកម្មាធិការជាបន្ទុករបស់ក្រសួងសុខាភិបាល ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងសមាសភាព ដូចក្នុងប្រការ១ខាងលើនេះ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ ក្រសួង ស្ថាប័ន
-ដូចប្រការ១
-ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com